
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 1.10 លោកយ៉ូហានបាទីស្ទ

Kids of Destiny®
Reaching the Next Generation

ជាយូរមកហើយមានស្ត្រីពីរនាក់ដែលត្រូវជាបងប្អូនជីដូនមួយនឹងគ្នា។ ម្នាក់ឈ្មោះម៉ារា ស្ត្រីម្នាក់ទៀតឈ្មោះ អេលីសាបិត។ អ្នកប្រហែលជាចាំពីរបៀបដែលទេវតាមកជួបម៉ារា ហើយប្រាប់នាងថា នាងនឹងមានកូនហើយទារកនោះជាព្រះរាជបុត្រារបស់ព្រះ។ ទេវតាក៏បានប្រាប់ទៅកាន់សាការីដែលជាប្តីរបស់អេលីសាបិតដែរ។ ទេវតាបានប្រាប់សាការីថា គាត់និងភរិយារបស់គាត់អេលីសាបិតនឹងមានកូន។ ទារករបស់ពួកគេត្រូវដាក់ឈ្មោះថា "យ៉ូហាន"។ លោកយ៉ូហាននឹងមានការងារពិសេសពីព្រះ។ គាត់គឺជាមនុស្សម្នាក់ដែលនឹងរៀបចំផ្លូវសម្រាប់ការយាងមកនៃព្រះរាជបុត្រារបស់ព្រះ គឺជាព្រះយេស៊ូវ។

លោកយ៉ូហាន គឺជាអ្នកដែលធ្វើបុណ្យជ្រមុជទឹក ឲ្យមនុស្សដែលចង់ងាកចេញពីអំពើបាបរបស់ពួកគេ។ គាត់នឹងជ្រមុជទឹកអោយពួកគេចូលទៅក្នុងទឹក ហើយលើកឡើងមកលើវិញ។ នេះជានិមិត្តរូបនៃការងាកចេញពីអំពើបាបរបស់ពួកគេ ហើយចាប់ផ្តើមជីវិតថ្មី។ វាដូចជាបានកើតជាថ្មី។ លោកយ៉ូហានរស់នៅក្នុងទីរហោស្ថាន។ គាត់មិនមានផ្ទះសម្រាប់រស់នៅទេ។ គាត់បរិភោគកណ្តូប និងទឹកឃ្មុំជាអាហារ។ មនុស្សជាច្រើនចង់ស្តាប់គាត់និយាយ ហើយស្តាប់គាត់បង្រៀនពួកគេពីរបៀបរស់នៅ។ គាត់បានបង្រៀនពួកគេឱ្យចែកចាយជាមួយអ្នកដទៃមិនថាជាសម្លៀកបំពាក់ ឬអាហាររបស់ពួកគេទេ។

លោកយ៉ូហានក៏បានបង្រៀនអ្នកប្រមូលពន្ធឲ្យស្មោះត្រង់និងមិនយកពន្ធហួសពីច្បាប់កំណត់ដែលពួកគេប្រមូលពន្ធពីបណ្តាជនដើម្បីបង់ពន្ធឲ្យរដ្ឋាភិបាល។ គាត់ក៏បានបង្រៀនទាហានឱ្យសប្បាយចិត្តនឹងអ្វីដែលពួកគេទទួល។ មនុស្សម្នាសួរលោកយ៉ូហានថា តើលោកពិតជាព្រះគ្រីស្ទឬ? លោកបានប្រាប់ពួកគេថាគាត់មិនមែនជាព្រះគ្រីស្ទដែលពួកគេទាំងអស់គ្នាកំពុងរង់ចាំនោះទេ។ គាត់មានប្រសាសន៍ថា "ខ្ញុំធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្សដោយបង្ហាញថា ពួកគេចង់ឈប់ធ្វើអំពើអាក្រក់ហើយចាប់ផ្តើមដើរតាមព្រះ។ ប៉ុន្តែព្រះយេស៊ូវដែលជាព្រះគ្រីស្ទនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាដោយព្រះវិញ្ញាណបរិសុទ្ធ។

ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះដ៏កំសាន្តចិត្តមកពីព្រះអម្ចាស់។ ទ្រង់នឹងនៅជាមួយអ្នកគ្រប់ពេលវេលា។ មនុស្សជាច្រើននៅថ្ងៃនោះបានទទួលបុណ្យជ្រមុជទឹកនៅក្នុងទឹក ហើយបានងាកចេញពីអំពើបាបរបស់ពួកគេ។ ព្រះយេស៊ូវ គឺជាផ្លូវដែលអាចឲ្យពួកគេទទួលការអត់ទោសបាបបាន។ នៅថ្ងៃបន្ទាប់ព្រះយេស៊ូវយាងមកជិតលោកយ៉ូហាន។ លោកយ៉ូហានពិតជារំភើបណាស់។ គាត់និយាយថា"មើល! នេះគឺជាព្រះមួយអង្គដែលយើងកំពុងតែរងចាំ! ទ្រង់អត់ទោសបាបឲ្យមនុស្សលោក! នេះគឺជាម្នាក់ដែលខ្ញុំបាននិយាយនោះ"។

យ៉ូហានបានធ្វើបុណ្យជ្រមុជទឹកឲ្យព្រះយេស៊ូវ។ បន្ទាប់មកលោកយ៉ូហានបានឃើញផ្ទៃមេឃបើកចំហ។ គាត់បានឃើញព្រះវិញ្ញាណបរិសុទ្ធដែលមើលទៅដូចជាសត្វព្រាបចុះមករកព្រះយេស៊ូវ។ បន្ទាប់មកគាត់បានឮព្រះសូរសៀងរបស់ព្រះអម្ចាស់ថា "នេះគឺជា កូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់" ។

នៅថ្ងៃបន្ទាប់លោកយ៉ូហានបានដើរជាមួយមិត្តភក្តិពីរនាក់របស់គាត់។ ពួកគេបានឃើញព្រះយេស៊ូវ។ លោកយ៉ូហានបានប្រាប់មិត្តរបស់គាត់ថា "មើល! នោះជាសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់។ មិត្តម្នាក់របស់គាត់ឈ្មោះអនទ្រេ។ អនទ្រេក៏បានដើរតាមព្រះយេស៊ូវ។ រឿងទាំងអស់នេះ បានកើតឡើងនៅក្នុងជីវិតរបស់លោកយ៉ូហានបាទីស្ទ! គាត់បានបំពេញការងារដែលព្រះបានឱ្យគាត់ធ្វើ។ **(លូកា៣, យ៉ូហាន ១)**

## 1.10 លោកយ៉ូហានបាទីស្ទ - សៀវភៅណែនាំសម្រាប់គ្រូបង្រៀន
## កំណត់សំគាល់

១) ទេវតាមួយរូបបានមកប្រាប់ ម៉ារា អំពីរឿងដែលនាងមានបុត្ររបស់ព្រះអម្ចាស់ ដែលនឹងត្រូវហៅថាព្រះយេស៊ូវ។ ហើយក៏មានទេវតាមកប្រាប់លោកសាការីថា គាត់និងប្រពន្ធគាត់ឈ្មោះអេលីសាបិត នឹងមានកូនប្រុសម្នាក់ហៅថាលោកយ៉ូហាន។
២) លោកយ៉ូហានមានការងារពិសេស។ គាត់គឺត្រូវរៀបចំមនុស្សសម្រាប់ពេលវេលាដែលព្រះយេស៊ូវនឹងយាងមករកពួកគេ។
៣) លោកយ៉ូហានបានប្រាប់ទៅកាន់ប្រជាជន អំពីរបៀបដែលពួកគេគួររស់នៅ ។ គាត់បានប្រាប់ពួកគេថាគាត់នឹងធ្វើពិធីជ្រមុជទឹកឲ្យពួកគេ។ នេះអាចបង្ហាញថា ពួកគេមានការសោកស្តាយចំពោះអ្វីដែលពួកគេបានធ្វើខុសហើយងាកចេញពីអំពើបាបរបស់ពួកគេ ។
៤) បណ្តាជនសួរលោកយ៉ូហានថា តើគាត់ជាព្រះគ្រីស្ទឬ? គាត់បាននិយាយថាគាត់មិនមែនទេ។ លោកយ៉ូហាន នឹងធ្វើពិធីជ្រមុជឲ្យគេក្នុងទឹក រីឯព្រះយេស៊ូវដែលជាព្រះគ្រីស្ទ នឹងធ្វើពិធីជ្រមុជទឹកឲ្យគេដោយនូវព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យគេអាចនៅជិតព្រះអម្ចាស់បាន ។
៥) យ៉ូហានក៏បានធ្វើបុណ្យជ្រមុជទឹកឲ្យព្រះយេស៊ូវដែរ។ គាត់បានឃើញព្រះវិញ្ញាណបរិសុទ្ធកំពុងតែយាងចុះមកសណ្ឋិតលទ្រង់គឺដូចជាសត្វព្រាប។ គាត់បានលឺព្រះមានបន្ទូលថា "នេះគឺជាកូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់"។

**សំណួរ:**

១) តើកូនរបស់ លោកសាការី និងលោកស្រីអេលីសាបិតមានឈ្មោះអ្វី?
២) តើការងារពិសេសរបស់លោកយ៉ូហានគឺអ្វី?
៣) ហេតុអ្វីបានជាលោកយ៉ូហានធ្វើបុណ្យជ្រមុជទឹកឲ្យបណ្តាជន?
៤) តើលោកយ៉ូហានជាព្រះគ្រីស្ទឬ?
៥) តើមានអ្វីកើតឡើងបន្ទាប់ពីលោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកឲ្យព្រះយេស៊ូវ?

**ចម្លើយ:**

១) កូនប្រុសរបស់លោកសាការី និងអ្នកស្រីអេលីលាបិតមានឈ្មោះថាយ៉ូហាន ។
២) លោកយ៉ូហានមានការងារពិសេសក្នុងការរៀបចំប្រជាជនសម្រាប់ពេលដែលព្រះយេស៊ូវនឹងមករកពួកគេ ។
៣) លោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកឲ្យគេដូច្នេះ ពួកគេនឹងងាកចេញពីអំពើបាបរបស់គេ ។
៤) លោកយ៉ូហានមិនមែនជាព្រះគ្រីស្ទទេ ។ ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។
៥) បន្ទាប់ពីលោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកជូនព្រះយេស៊ូវហើយគាត់បានឃើញព្រះវិញ្ញាណបរិសុទ្ធយាងចុះមកសណ្ឋិតលើទ្រង់មើលទៅដូចជាសត្វព្រាប។គាត់បានឮព្រះមានបន្ទូលថា"នេះគឺជាកូនស្ងួនភ្ងារបស់អញជាទីពេញចិត្តអញណាស់"។



www.kidsofdestiny.org